# គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)

Committee For Free And Fair Elections In Cambodia (COMFREL)

ខុមហ្វ្រែល COMFREL

ទីស្នាក់ការកណ្តាល ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ទឹកល្អក់ ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

Central Office: #138, St. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.

P.O. Box 1145, Tel: (855) 23 884 150/12 942 019, Fax: (855) 23 883 750 E-mail: comfrel@online.com.kh, comfrel@comfrel.org or comfreladmin@online.com.kh, Site : www.comfrel.org



**គណៈកម្មាធិការនាយក**

**BOARD OF DIRECTORS**

1. លោក **ធុន សារាយ**
**Mr. THUN Saray**
ប្រធានគណៈកម្មាធិការនាយក
និងជាប្រធាន **ADHOC**

2. លោក **សុក សំអឿន**
**Mr. SOK Sam Oeun**
អនុប្រធានគណៈកម្មាធិការនាយក
និងជានាយក **CDP**

3. លោក **យឹម ប៉ូ**
**Mr. YIM Po** អគ្គហេរញ្ញិក
និងជានាយក **CCPCR**

4. អ្នកស្រី **ស៊ុន ចាន់សែន**
**Mrs. SUN Chansen** សមាជិកា
និងជាប្រធាន **KYA**

5. លោក **យង់ គិមអេង**
**Mr. YONG Kim Eng** សមាជិក
និងជានាយក **PDP-Center**

6. លោក **មុំ សារិន**
**Mr. MOM Sarin** សមាជិកា
និងជានាយក **HRCDO**

7. អ្នកស្រី **ទីវ សារាយេត**
**Ms. TIV Sarayet** សមាជិកា
និងជាសហនាយិកា **WMC**

8. កញ្ញា **សយ សារា វឌ្ឍនី**
**Miss. SAY Sara Vathany**
សមាជិកា
និងជានាយិកា **CWCC**

9. លោក **គីម សុវណ្ណ**
**Mr. KIM Sovann** សមាជិក
និងជានាយក **VIGILANCE**

10. នាយក **LAC (NA)**

11. នាយក **KKKHRO (NA)**

12. អ្នកស្រី **ពឹង យក់ហៀប**
**Ms. PEUNG Yok Hiep** សមាជិកា
ជាឥស្សរជន Dignitary

13. លោក **ស៊ីន សែត**
**Mr. SEN Set** សមាជិក
ជាឥស្សរជន Dignitary


ស.ប្រ.ក.ព/លេខ ០៩/១០ គ.ប.ស.យ/អ.ក

# សេចក្តីប្រកាសព័ត៌មាន

# ស្តីពី

# លទ្ធផលវាយតម្លៃរបស់ម្ចាស់ឆ្នោតទៅលើការអនុវត្តន៍លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាព ក្នុងខេត្ត កំពង់ឆ្នាំង

*ភ្នំពេញ, ថ្ងៃទី ២៧ ខែសីហា ឆ្នាំ ២០១០*

ម្ចាស់ឆ្នោតនៅខេត្តកំពង់ឆ្នាំងប្រមាណ ១00នាក់ ក្នុងនោះមាន ស្ត្រី ៣៦% មកពីសហគមន៍ ដីធ្លី នេសាទ,,,,,,, អង្គការមិនមែនរដ្ឋាភិបាលនានា អាជីវករ/ពាណិជ្ជករ មន្ត្រីរាជការ សិស្ស/និស្សិត កសិករ ដែលមកពីគ្រប់ស្រុកនិងក្រុងក្នុងខេត្តកំពង់ឆ្នាំង បានបង្ហាញពីការពេញចិត្តទៅលើការអនុវត្តន៍ការងាររបស់មន្ត្រីជាប់ឆ្នោត ក្នុងការអនុវត្តន៍លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តកំពង់ឆ្នាំង ដែលលក្ខខណ្ឌសន្ទស្សន៍ភាគច្រើនបានអនុវត្តបានខ្លះៗ។

ម្ចាស់ឆ្នោតភាគច្រើន បានអោយពិន្ទុការអនុវត្តន៍លក្ខខណ្ឌសន្ទស្សន៍ក្នុងចន្លោះធ្វើបានខ្លះ( ពិន្ទុ ២) ដូចជា ចំនុចដែលទាក់ទងទៅនឹងការផ្តល់ដីសម្បទានសង្គមកិច្ច ដែលរដ្ឋាភិបាលកំពុងអនុវត្តផែនការដែលមានទិសដៅ រយៈពេល ៤ឆ្នាំ ចាប់ពីឆ្នាំ ២00៨ ដល់ ២0១២ ដែលរកបានចំនួន ២៧២៧ ហិកតា ហើយឥឡូវកំពុងស្ថិតនៅការកំណត់នូវអត្តសញ្ញាណដី។ រីឯចំនុចដែលទាក់ទងទៅនឹង ការចេញប្លង់កម្មសិទ្ធិអោយបានគ្រប់ៗគ្នា អាជ្ញាធរខេត្តកំពង់ឆ្នាំង បានចេញប្លង់កម្មសិទ្ធដីអោយប្រជាពលរដ្ឋ ដោយគិតមកដល់ខែ កក្កដា ឆ្នាំ ២0១0 នេះ គំរោងនេះត្រូវបានអនុវត្តបាន ២៣,៧៨% ។ ចំណែក អត្រាការប្រាក់អោយនៅត្រឹម ១.៥% ក៏ឃើញចេញជាលទ្ធផលដែរ ប៉ុន្តែទាល់តែប្រាក់កម្ចីចាប់ពី ២000 ដុល្លារឡើងទៅ ។ ការបញ្ចុះតំលៃសេវាសុខភាព ឬមិនគិតថ្លៃសំរាប់អ្នកក្រក៏បានអនុវត្ត ប៉ុន្តែម្ចាស់ឆ្នោតក៏បានលើកឡើងថា មណ្ឌលសុខភាពខ្លះមិនអនុវត្តតាមគោលការណ៍ និង ក្រមសីលធម៌របស់ក្រុមគ្រូពេទ្យមួយចំនួននៅមានលក្ខណៈខ្សោយ ។

ចំនុចដែលម្ចាស់ឆ្នោតភាគច្រើន បានអោយពិន្ទុ ៣ ដែលបានធ្វើពាក់កណ្តាលនោះ គឺទាក់ទងទៅនឹងការទប់ស្កាត់បទល្មើសនេសាទដែលអាជ្ញាធរខេត្តបាន បង្ក្រាបបទល្មើសបាន ២៣៨ ករណី ហើយបានបង្កើតជាគណៈកម្មការ ៥ ធំៗ ដើម្បីបង្ក្រាបបទល្មើសនេសាទ ។

នេះតំលៃអគ្គីសនីគឺ ១៦00 រៀលក្នុងមួយគីឡូវ៉ាត់ម៉ោង ។ ការតម្លើងប្រាក់ខែដល់កម្មករមិនទាន់បានអនុវត្តទៅតាមអ្វីដែលប្រជាពលរដ្ឋទាមទារអោយបាន៧0ដុល្លារ/ខែ (ប្រាក់ខែគោល)។ ជាពិសេសច្បាប់ស្តីពី

លក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ម្ចាស់ឆ្នោតវាយតំលៃថាមិនទាន់មាននៅឡើយ ។

អ្នកតំណាងរាស្ត្រ **ឃី វណ្ណដេត** និងសមាជិកក្រុមប្រឹក្សាខេត្ត ឯកឧត្តម **ឡុង ឈុនឡៃ** ឯកឧត្តម **ទឹម ប៊ុណ្ណា** ព្រមទាំង ឯកឧត្តម **ទាំ សារី** បានលើកឡើងពីការខិតខំប្រឹងប្រែង និងសំណូមពរដល់ប្រជាពលរដ្ឋអោយជួយសហការគ្នា ក្នុងការអភិវឌ្ឍន៍ប្រទេសជាតិ ជាពិសេសខេត្តកំពង់ឆ្នាំង ។

ម្ចាស់ឆ្នោតធ្វើការផ្តល់ពិន្ទុទៅលើការបំពេញ/សម្រេចបានទៅលើចំនុចនីមួយៗដែលម្ចាស់ឆ្នោត ដែលមានន័យថា "ពិន្ទុ ១ សំរាប់ការមិនបានធ្វើទាល់តែសោះ ឬបានធ្វើតិចតួច(ច្រើនបំផុតត្រឹម ២0%)" "ពិន្ទុ ២ សំរាប់ការបានធ្វើខ្លះ (២១%-៤0%)" "ពិន្ទុ ៣ សំរាប់ការបានធ្វើមធ្យម ឬបានធ្វើពាក់កណ្តាល (៤១%-៦0%)" "ពិន្ទុ ៤ សំរាប់ការបានធ្វើច្រើន (៦១%-៨0%)" និង "ពិន្ទុ ៥ សំរាប់ ការបានធ្វើស្ទើរតែទាំងស្រុង ឬបានធ្វើទាំងស្រុង (៨១%-១00%)"។

ជាលទ្ធផល ម្ចាស់ឆ្នោតប្រមាណ ១00នាក់ បានផ្តល់ពិន្ទុទៅលើការសម្រេចបានរបស់មន្ត្រីជាប់ឆ្នោតទៅលើចំនុចនីមួយៗ ដែលម្ចាស់ឆ្នោតបានកំណត់កាលពីឆ្នាំ២00៩ ដូចខាងក្រោមៈ

| **ភាគរយនៃចំនួនម្ចាស់ឆ្នោតបានផ្តល់ពិន្ទុលើការអនុវត្តន៍របស់មន្ត្រីជាប់ឆ្នោតនៅលើចំនុចនីមួយៗនៃ<br>លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនាំឲជប់នៅក្នុងខេត្តកំពង់ឆ្នាំង** |
|---|
| ១) សូមឱ្យរដ្ឋាភិបាលទប់ស្កាត់បទល្មើសនេសាទ និងការកាប់ព្រៃឈើឱ្យបាន ១00% ក្នុងខេត្តកំពង់ឆ្នាំងចាប់ពីឆ្នាំ ២0១0 តទៅ ។<br>**ពិន្ទុ ១ (២២%) ពិន្ទុ ២ (២៤%) ពិន្ទុ ៣ (៣៩%) ពិន្ទុ ៤ (១៣%) ពិន្ទុ ៥ (១%)**<br>**៣៩% ភាគច្រើននៃម្ចាស់ឆ្នោតផ្តល់ពិន្ទុ ៣ ចំពោះចំនុចនេះ ។** |
| ២) សូមឱ្យរដ្ឋាភិបាលផ្តល់ដីសម្បទានសង្គមកិច្ចសំរាប់ការដាំដំណាំដល់គ្រប់គ្រួសារប្រជាពលរដ្ឋក្រីក្រដែលខ្វះខាតដីក្នុងខេត្តកំពង់ឆ្នាំង ឱ្យបានត្រឹមឆ្នាំ ២0១0។<br>**ពិន្ទុ ១ (៤២%) ពិន្ទុ ២ (៤៥%) ពិន្ទុ ៣ (១១%) ពិន្ទុ ៤ (១%) ពិន្ទុ ៥ (0%)**<br>**៤៥% ភាគច្រើននៃម្ចាស់ឆ្នោតផ្តល់ពិន្ទុ ២ ចំពោះចំនុចនេះ ។** |
| ៣) ត្រូវមានការដេញថ្លៃជាសាធារណៈចំពោះការផ្គត់ផ្គង់ថាមពលអគ្គិសនីសម្រាប់ទូទាំងខេត្តកំពង់ឆ្នាំងចាប់ពីឆ្នាំ ២0១១ និងបញ្ចុះតំលៃអគ្គិសនី មកត្រឹម ៨00 រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង អោយបានចាប់ពីឆ្នាំ ២0១0តទៅ។<br>**ពិន្ទុ ១ (៧៥%) ពិន្ទុ ២ (១៩%) ពិន្ទុ ៣ (៥%) ពិន្ទុ ៤ (១%) ពិន្ទុ ៥ (0%)**<br>**៧៥% ភាគច្រើននៃម្ចាស់ឆ្នោតផ្តល់ពិន្ទុ ១ ចំពោះចំនុចនេះ ។** |
| ៤) រដ្ឋាភិបាលត្រូវចេញច្បាប់ប្រឆាំងអំពើពុករលួយអោយចេញនៅដើមឆ្នាំ ២0១0។<br>**ពិន្ទុ ១ (១៩%) ពិន្ទុ ២ (៣0%) ពិន្ទុ ៣ (១៤%) ពិន្ទុ ៤ (១៥%) ពិន្ទុ ៥ (២២%)**<br>**៣0% ភាគច្រើននៃម្ចាស់ឆ្នោតផ្តល់ពិន្ទុ ២ ចំពោះចំនុចនេះ ។** |
| ៥) សូមជួយជំរុញការដោះស្រាយទំនាស់ដីធ្លី ដោយចេញប្លង់កម្មសិទ្ធិឱ្យបានគ្រប់ៗគ្នាទូទាំងខេត្តកំពង់ឆ្នាំង យ៉ាងយូរត្រឹមឆ្នាំ ២0១៣ ។<br>**ពិន្ទុ ១ (១៣%) ពិន្ទុ ២ (៦៤%) ពិន្ទុ ៣ (២៣%) ពិន្ទុ ៤ (១%) ពិន្ទុ ៥ (0%)** |

| |
|---|
| **៦៤% ភាគច្រើននៃម្ចាស់ឆ្នោតផ្តល់ពិន្ទុ ២ ចំពោះចំនុចនេះ ។** |
| ៦) សូមផ្តល់វគ្គបណ្តុះបណ្តាលពីបច្ចេកទេសកសិកម្មដល់ប្រជាកសិករក្នុងខេត្តឱ្យបាន ១0វគ្គ ក្នុងមួយឆ្នាំអោយ បានគ្រប់ភូមិក្នុងខេត្ត កំពង់ឆ្នាំង ចាប់ពីឆ្នាំ ២០១០ តទៅ ។<br>**ពិន្ទុ ១ (៦%) ពិន្ទុ ២ (២៩%) ពិន្ទុ ៣ (៤៧%) ពិន្ទុ ៤ (១៥%) ពិន្ទុ ៥ (២%)**<br>**៤៧% ភាគច្រើននៃម្ចាស់ឆ្នោតផ្តល់ពិន្ទុ ៣ ចំពោះចំនុចនេះ ។** |
| ៧) សូមឱ្យរដ្ឋាភិបាលជួយធ្វើអន្តរាគមន៍ដល់វិស័យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅក្នុងខេត្តកំពង់ឆ្នាំងបញ្ចុះតំលៃអត្រាការប្រាក់មកនៅត្រឹម តែ ១.៥ %/ ខែ ដើម្បីជួយសំរួលប្រជាពលរដ្ឋក្រីក្រចាប់ពីឆ្នាំ ២០១០ តទៅ។<br>**ពិន្ទុ ១ (៣៥%) ពិន្ទុ ២ (៤៣%) ពិន្ទុ ៣ (១៨%) ពិន្ទុ ៤ (៣%) ពិន្ទុ ៥ (0%)**<br>**៤៣% ភាគច្រើននៃម្ចាស់ឆ្នោតផ្តល់ពិន្ទុ ២ ចំពោះចំនុចនេះ ។** |
| ៨) សូមឱ្យរដ្ឋាភិបាលជួយធ្វើបទអន្តរាគមន៍ដល់រោងចក្រនានានៅក្នុងខេត្ត កំពង់ឆ្នាំង ដោយតម្លើងប្រាក់ខែ ដល់កម្មករឱ្យបានសមស្របទៅនឹងតម្រូវការទីផ្សារ យ៉ាងហោចណាស់ចាប់ពី ៧0ដុល្លារ/ខែ (ប្រាក់ខែគោល) ចាប់ពីឆ្នាំ ២០១០ តទៅ ។<br>**ពិន្ទុ ១ (៥៨%) ពិន្ទុ ២ (៣៤%) ពិន្ទុ ៣ (៦%) ពិន្ទុ ៤ (១%) ពិន្ទុ ៥ (0%)**<br>**៥៨% ភាគច្រើននៃម្ចាស់ឆ្នោតផ្តល់ពិន្ទុ ១ ចំពោះចំនុចនេះ ។** |
| ៩) បញ្ចុះតំលៃសុខភាពអោយទាប ឬមិនគិតថ្លៃសំរាប់អ្នកក្រ អោយបាន៨0ភាគរយនៃតម្លៃបច្ចុប្បន្ន [ ខែ កញ្ញា ២០0៩] នៅតាមគ្រប់មណ្ឌល សុខភាព និងមន្ទីរពេទ្យបង្អែកអោយបាននៅឆ្នាំ ២០១០ តទៅ។<br>**ពិន្ទុ ១ (២៩%) ពិន្ទុ ២ (៣0%) ពិន្ទុ ៣ (២៨%) ពិន្ទុ ៤ (១២%) ពិន្ទុ ៥ (១%)**<br>**៣0% ភាគច្រើននៃម្ចាស់ឆ្នោតផ្តល់ពិន្ទុ ២ ចំពោះចំនុចនេះ ។** |
| ១0) រដ្ឋាភិបាលត្រូវបង្កើតលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញាអោយចេញនៅពាក់កណ្តាលឆ្នាំ ២០១០។<br>**ពិន្ទុ ១ (៩0%) ពិន្ទុ ២ (៨%) ពិន្ទុ ៣ (២%) ពិន្ទុ ៤ (0%) ពិន្ទុ ៥ (0%)**<br>**៩0% ភាគច្រើននៃម្ចាស់ឆ្នោតផ្តល់ពិន្ទុ ១ ចំពោះចំនុចនេះ ។** |
| ១១) **ចំនុចរួមៈ តើអ្នកពេញចិត្តការអនុវត្តរបស់មន្ត្រីជាប់ឆ្នោតទៅលើលក្ខខណ្ឌសន្ទស្សន៍ទាំង១0 កម្រិតណា?**<br>☐ ១) មិនពេញចិត្តទាល់តែសោះ,☐២) ពេញចិត្តតិចតួច, ☐ ៣) ពេញចិត្តគួរសម, ☐៤) ពេញចិត្តច្រើន, ☐៥) ពេញចិត្តទាំងស្រុង<br>**ពិន្ទុ (៦%) ពិន្ទុ (២៤%) ពិន្ទុ (៤២%) ពិន្ទុ (១៨%) ពិន្ទុ ៥ (១0%)**<br>**៤២% ភាគច្រើននៃម្ចាស់ឆ្នោតពេញចិត្តទៅលើការអនុវត្តរបស់មន្ត្រីជាប់ឆ្នោតទៅលើលក្ខខណ្ឌសន្ទស្សន៍ទាំង ១0** |

ការវាយតម្លៃនេះ ត្រូវបានធ្វើឡើងដោយម្ចាស់ឆ្នោតក្នុងវេទិកាម្ចាស់ឆ្នោតដែលរៀបចំដោយគណៈកម្មាធិការ **ខុមហ្វ្រែល** នៅថ្ងៃទី ១២ ខែសីហា ឆ្នាំ២០១០នៅខេត្តកំពង់ឆ្នាំង ដោយមានកិច្ចសហការជាមួយសមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC), សមាគមយុវជនខ្មែរ (KYA) និងអង្គការការពារសិទ្ធិមនុស្សខ្មែរកម្ពុជាក្រោម (KKKHRA) ។

*សម្រាប់ព័ត៌មានបន្ថែមៗសូមទាក់ទងៈ*

- លោក **សុខ ពិទូរ្យ** អ្នកសម្របសម្រួលផ្នែកអង្កេតខុមហ្វ្រែល ទូរស័ព្ទៈ ០៨៩ ៥២៥ ៤៤៦